# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

**អគ្គនាយកដ្ឋានព័ត៌មាន និងសោតទស្សន៍**

លេខ : ២៤៧ អពស.ព.ស

## សេចក្តីជូនដំណឹង

អគ្គនាយកដ្ឋានព័ត៌មាន និងសោតទស្សន៍ នៃក្រសួងព័ត៌មាន មានកិត្តិយសសូមជម្រាបជូន អ្នកសារព័ត៌មានជាតិ អន្តរជាតិទាំងអស់ មេត្តាជ្រាបថា ក្រសួងមុខងារសាធារណៈ នឹងរៀបចំកិច្ចប្រជុំសហប្រតិបត្តិការអាស៊ានលើកទី២៣ និងអាស៊ានបូកបីលើកទី៨ ស្តីពីកិច្ចការមុខងារសាធារណៈ និងព្រឹត្តិការណ៍ពាក់ព័ន្ធសម្រាប់ឆ្នាំ២០២៦ ក្រោមមូលបទ «នវានុវត្តន៍សម្រាប់ការផ្តល់សេវាសាធារណៈឱ្យកាន់តែល្អប្រសើរឡើង» **(Innovation for Better Service Delivery)** ដែលនឹងប្រព្រឹត្តទៅក្នុងរយៈពេល ០៣ ថ្ងៃ ចាប់ពីថ្ងៃទី៣-៥ ខែសីហា ឆ្នាំ២០២៦ នៅសណ្ឋាគារសុខា ខេត្តសៀមរាប (Sokha Siem Reap Resort & Convention Center)។ កិច្ចប្រជុំនេះ នឹងប្រព្រឹត្តទៅដូចខាងក្រោម៖

កាលបរិច្ឆេទ និងកម្មវិធី៖

- ថ្ងៃទី៣ ខែសីហា ឆ្នាំ២០២៦ កិច្ចប្រជុំមន្ត្រីជាន់ខ្ពស់ស្តីពីកិច្ចសហប្រតិបត្តិការអាស៊ានលើវិស័យមុខងារសាធារណៈលើកទី២៣ (23rd ACCSM SOM) និងកិច្ចប្រជុំមន្ត្រីជាន់ខ្ពស់លើកទី៨ នៃកិច្ចសហប្រតិបត្តិការអាស៊ានបូកបី លើវិស័យមុខងារសាធារណៈ (8th ACCSM+3 SOM)
- ថ្ងៃទី៤ ខែសីហា ឆ្នាំ២០២៦ វេទិកាអភិបាលកិច្ចល្អ និងដំណើរទស្សនកិច្ចវប្បធម៌
- ថ្ងៃទី៥ ខែសីហា ឆ្នាំ២០២៦ ពិធីបើក ក្រោមអធិបតីដ៏ខ្ពង់ខ្ពស់របស់ **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា**

ដើម្បីចូលរួមយកព័ត៌មានក្នុងព្រឹត្តិការណ៍ខាងលើ សូមអ្នកសារព័ត៌មានជាតិ អន្តរជាតិ ចូលរួមចុះឈ្មោះជាមុនតាមរយៈគេហទំព័រ www.accsmcambodia.info ចាប់ពីថ្ងៃជូនដំណឹងនេះ រហូតដល់ថ្ងៃទី១ ខែសីហា ឆ្នាំ២០២៦ ដើម្បីយកបណ្ណសម្គាល់។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូមអ្នកសារព័ត៌មានជាតិ អន្តរជាតិទាំងអស់ ជ្រាបជាព័ត៌មាន។

ថ្ងៃព្រហស្បតិ៍ ១៣កើត ខែស្រាពណ៍ ឆ្នាំមមី អដ្ឋស័ក ព.ស. ២៥៧០

រាជធានីភ្នំពេញ ថ្ងៃទី ៣០ ខែកក្កដា ឆ្នាំ២០២៦

ស្កេនទីនេះ ដើម្បីបំពេញពាក្យ

https://docs.google.com/forms/d/e/1FAIpQLSdRqCUFczAxm7hCtTgRPAJbBUpDSWDUW-yYhqeJF4hyjFPZmQ/viewform

ស្កេនទីនេះ ដើម្បីសម្អាសប្រតិកូ

https://docs.google.com/forms/d/e/1FAIpQLSdz5Cb3mBkPhhLumHjq9j-UjGujejvRPXUDNBepATkWamUG1g/viewform?usp=publish-editor

អគារលេខ ៦២ មហាវិថីព្រះមុនីវង្ស សង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ. E-mail: info@inb.gov.kh.www.inb.gov.kh